**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សេចក្តីប្រកាសព័ត៌មាន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូទៅចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ និងបញ្ចុះសពរបស់ **ឯកឧត្តម ង្វៀន ហ្វ៊ូចុង** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ២០២៤ នៅរដ្ឋធានីហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា**ទាំងមូល សូមសម្តែងនូវការសោកស្តាយ ប្រកបដោយមនោសញ្ចេតនាអាឡោះអាល័យជាទីបំផុត ចំពោះមរណភាពរបស់ **ឯកឧត្តមអគ្គលេខាធិការបក្ស** និងសូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំចំពោះប្រជាជនវៀតណាម ជាពិសេសចំពោះក្រុមគ្រួសារនៃសព។ **ឯកឧត្តម ង្វៀន ហ្វ៊ូចុង** គឺជារដ្ឋបុរសដ៏ឈ្លាសវៃ និងជាអ្នកនយោបាយដ៏ទន់ភ្លន់ និងសុភាពរាបសា មានបទពិសោធន៍នយោបាយយ៉ាងសម្បូរបែប ដែលបានធ្វើការលះបង់ពេញមួយជីវិត ដើម្បីបម្រើបុព្វហេតុរបស់បក្សកុម្មុយនីស្តវៀតណាម ប្រជាជន និងប្រទេសជាតិវៀតណាម។ ក្រោមការដឹកនាំរបស់ **ឯកឧត្តមអគ្គលេខាធិការបក្ស** ចំណងមិត្តភាពដ៏ស្អិតរមួត និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងវៀតណាមត្រូវបានលើកកម្ពស់យ៉ាងខ្លាំងនៅគ្រប់កម្រិត ដែលបានចូលរួមចំណែកជាវិជ្ជមានដល់សន្តិភាព ស្ថិរភាព និងវិបុលភាព របស់ប្រទេសទាំងពីរ និងតំបន់។

ឆ្លៀតក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ គណៈប្រតិភូក៏ជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម តូ ឡឹម** ប្រធានរដ្ឋវៀតណាម ឯកឧត្តម **ត្រឹន ថាញ់មិន** ប្រធានរដ្ឋសភាវៀតណាម ឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីវៀតណាម និងឯកឧត្តម **លឿង គឿង** ប្រធានគណៈលេខាធិការដ្ឋានមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅទីក្រុងហាណូយ ដើម្បីផ្លាស់ប្តូរទស្សនវិស័យនៃកិច្ចសហប្រតិបត្តិការ ក្នុងការបន្តទំនាក់ទំនងដ៏ល្អ ជាប្រពៃណីរវាងគណបក្ស រដ្ឋ និងប្រជាជននៃប្រទេសទាំងពីរ។

ក្នុងជំនួបជាមួយ **ឯកឧត្តម តូ ឡឹម** ប្រធានរដ្ឋវៀតណាម នាថ្ងៃទី២៥ **ឯកឧត្តមប្រធានរដ្ឋ** បានគូសបញ្ជាក់ថា មិត្តភាពដែលមានជាង ១១សតវត្សរ៍ កន្លងទៅរវាង **ឯកឧត្តម ង្វៀន ហ្វ៊ូចុង** ដែលបានធ្វើការជាមួយ **សម្តេចតេជោ ហ៊ុន សែន** គឺពិតជាមានតម្លៃខ្លាំងណាស់ ហើយ**ឯកឧត្តមប្រធានរដ្ឋ** នឹងបន្តនូវការកិច្ចដែល **ឯកឧត្តមអគ្គលេខាធិការបក្ស** បានបន្សល់ទុក រួមមានស្នាដៃនៃការកសាងប្រទេស ក៏ដូចជាការកសាងមិត្តភាពជាបងប្អូន ជាមិត្តជិតខាងល្អរវាងកម្ពុជា វៀតណាម ហើយនឹងពង្រឹងពង្រីកបន្ថែមទៀត សម្រាប់មនុស្សជំនាន់ក្រោយ។

នៅល្ងាចថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ **គណៈប្រតិភូកម្ពុជា**បានបន្តជួបពិភាក្សាការងារនិងសម្តែងការគួរសមជាមួយឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីវៀតណាម។ ភាគីទាំងពីរបានជូនពរគ្នាទៅវិញទៅមក និងបញ្ជាក់នូវទំនុកចិត្តដែលកើតចេញពីការលះបង់ និងការសាមគ្គីគ្នាគ្រប់ដំណាក់កាល ដូច្នេះហើយភាគីទាំងពីរនឹងបន្តពូនជ្រំនូវមិត្តភាពនេះ ឱ្យបានយូរអង្វែងបន្តទៀត ជាពិសេសប្រពៃណីដែលនាយករដ្ឋមន្ត្រី ដែលបច្ចុប្បន្នមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជា **ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រីឡាវ និង**ឯកឧត្តម ផាម មិញជីញ** នាយករដ្ឋមន្ត្រីវៀតណាម តែងតែជួបគ្នាគ្រប់ពេលវេលា និងគ្រប់វេទិកាអន្តរជាតិ។ ភាគីទាំងពីរបន្តគាំទ្រគ្នានិងបំពេញគ្នាទៅវិញទៅមក ធ្វើយ៉ាងណាឱ្យពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការទាំងអស់មាន

ការកើនឡើង ជាពិសេសភាគីកម្ពុជា ជូនពរភាគីវៀតណាមឱ្យសម្រេចបានជាប្រទេសអភិវឌ្ឍន៍ នៅឆ្នាំ២០៣០ និងជាប្រទេសដែលចូលទៅក្នុងកម្រិតមហាសេដ្ឋកិច្ចទាំង២០ របស់ពិភពលោក។ ភាគីវៀតណាម ក៏បានជូនពរកម្ពុជាទទួលបានជោគជ័យចំពោះទស្សនៈវិស័យរបស់**សម្តេចតេជោ** និងការដឹកនាំរបស់**សម្តេចបវរធិបតី ហ៊ុន ម៉ាណែត** ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលខ្ពស់ នៅឆ្នាំ២០៥០។ **ភាគីវៀតណាម** ឯកភាពតាមសំណើរបស់**សម្តេចតេជោ** ដើម្បីបន្តផ្គត់ផ្គង់អគ្គិសនីដល់កម្ពុជា ២៥០មេហ្គាវ៉ាត់ និងបង្កើនការផ្គត់ផ្គង់ថាមពលរហូតដល់ ៤០០មេហ្គាវ៉ាត់ ឬក៏លើស ៤០០មេហ្គាវ៉ាត់ ដើម្បីបំពេញតម្រូវការក្នុងដំណាក់កាលនៃការអភិវឌ្ឍឧស្សាហកម្ម ៤.០។

**ឯកឧត្តម លឿង គឿង** ប្រធានគណៈលេខាមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ក៏បានជួបសម្តែងការគួរសម និងទទួលអាហារពេលល្ងាចជាមិត្តភាព ជូនចំពោះ**សម្តេចតេជោ** និងគណៈប្រតិភូកម្ពុជា។ ភាគីទាំងពីរគោរពចំពោះគុណតម្លៃរបស់ **ឯកឧត្តមអគ្គលេខាធិការ** ជាឥស្សរជនគំរូ និងជាការចងចាំរបស់ប្រជាជនវៀតណាម ក្នុងការដឹកនាំបក្ស និងរដ្ឋវៀតណាមឱ្យមានការជឿនលឿនមកទល់បច្ចុប្បន្ន។ ភាគីទាំងពីរ បានផ្លាស់ប្តូរគ្នាប្រកបដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ បន្តយកចិត្តទុកដាក់ខ្ពស់ចំពោះសាមគ្គីភាព បង្កើននូវការចងចាំនៃមិត្តភាពនិងការតស៊ូពីអតីតកាល ហើយបានឯកភាពគ្នាបន្តកិច្ចសហប្រតិបត្តិការរវាងបក្សទាំងពីរកាន់តែជឿនលឿន ដោយធ្វើការបំពេញគ្នា និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍ និងការរីកចម្រើនរបស់គ្នាទៅវិញទៅមក។ **ឯកឧត្តម**បានទទួលយកការអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា និងឯកភាពក្នុងការបន្តការផ្លាស់ប្តូរគណៈប្រតិភូគណបក្សគ្រប់កម្រិត ជាពិសេសយុវជនគណបក្សជំនាន់ក្រោយ ដើម្បីបង្កើននូវមិត្តភាព និងការជឿទុកចិត្តគ្នាទៅវិញទៅមក។

នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ គណៈប្រតិភូកម្ពុជា បានបន្តជួបពិភាក្សាការងារជាមួយនឹង ឯកឧត្តម **ត្រឹន ថាញ់មិន** ប្រធានរដ្ឋសភាវៀតណាម។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការនៃស្ថាប័ននីតិបញ្ញត្តិនៃប្រទេសទាំងពីរ តាមរយៈការផ្លាស់ប្តូររវាងគណៈកម្មការជំនាញនានា និងអគ្គលេខាធិការដ្ឋានរបស់រដ្ឋសភា និងព្រឹទ្ធសភានៃប្រទេសទាំងពីរ ក៏ដូចជាការផ្លាស់ប្តូរបទពិសោធន៍នៃការកសាងច្បាប់។ ភាគីទាំងពីរក៏បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលជាផ្លែផ្កានាពេលកន្លងមក តាមរយៈកិច្ចសហការជាប្រចាំ និងការគាំទ្រគ្នាទៅវិញទៅមកនៅក្នុងវេទិកាសភាពហុភាគី។

ទាំងថ្នាក់ដឹកនាំបក្ស រដ្ឋ និងរដ្ឋសភាវៀតណាម បានសម្តែងនូវមនោសញ្ចេតនាដ៏ជ្រាលជ្រៅបំផុតចំពោះ**សម្តេចតេជោ ហ៊ុន សែន** ដែលបានអញ្ជើញមកចូលរួមដោយផ្ទាល់ ទាំងការគោរពវិញ្ញាណក្ខន្ធ និងបន្តចូលរួមក្នុងពិធីបញ្ចុះសព។ ការបន្តវប្បធម៌នៃកិច្ចសហប្រតិបត្តិការដ៏ជ្រាលជ្រៅរវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**ឯកឧត្តមអគ្គលេខាធិការបក្ស ង្វៀន ហ៊្វូចុង** គឺជាមរតកសម្រាប់ថ្នាក់ដឹកនាំបក្ស រដ្ឋ និងសភា ក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនៃប្រទេសទាំងពីរ បក្សទាំងពីរ រដ្ឋទាំងពីរ និងប្រជាជនទាំងពីរ ដែលបានកសាងឡើងជាមួយនឹងទំនុកចិត្តដ៏ជ្រាលជ្រៅ និងស្មោះត្រង់ ការគោរពគ្នា និងការយោគយល់គ្នាក្នុងនាមជាមិត្តជិតខាងល្អជាប្រពៃណី ដែលមិនត្រឹមតែរវាងកម្ពុជា និងវៀតណាមទេ ក៏សម្តែងនូវមិត្តភាពល្អរវាងកម្ពុជា វៀតណាម ឡាវផងដែរ ដើម្បីឆ្ពោះទៅកាន់អនាគតកាល នៃតំបន់ដែនប្រកបដោយសន្តិភាព និងការអភិវឌ្ឍ។

ថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤